

# ការវាយតម្លៃដែលដឹកនាំដោយប្រទេសលើកម្មវិធីអាហារូបករណ៍អប់រំថ្នាក់ជាតិនៃក្រសួងអប់រំ យុវជន និងកីឡានៅកម្ពុជា (២០១៥-២០១៨)

## ខែ ឧសភា ឆ្នាំ ២០១៩

រូបថត: © UNICEF Cambodia /2018/Todd Brown

## របាយការណ៍វាយតម្លៃសង្ខេប

ក្នុងបណ្តាឆ្នាំថ្មីៗនេះ កម្ពុជាសម្រេចបានសមិទ្ធផលគួរឲ្យចាប់អារម្មណ៍លើកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និង ការកែលម្អនៅក្នុងការទទួលបានការអប់រំ។ ដូចមានបង្ហាញជូនក្នុងរូបទី ១ ចំនួនកុមារនៅក្រៅសាលារៀននៅកម្ពុជាមានកម្រិតទាបជាងកម្រិតមធ្យមនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (៥ ភាគរយ នៅបឋមសិក្សា និង ១៤ ភាគរយនៅមធ្យមសិក្សាបឋមភូមិនៅក្រៅសាលានៅកម្ពុជា ធៀបជាមួយនឹង ៦ ភាគរយ និង ១៥ ភាគរយក្នុងតំបន់)។ ប៉ុន្តែ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ជាពិសេស សម្រាប់កុមារា នៅមានលក្ខណៈមិនល្អនៅឡើយនៅកម្ពុជា ដោយសារមានតែ ៧៦ ភាគរយប៉ុណ្ណោះដែលបានបញ្ចប់បឋមសិក្សាក្នុងឆ្នាំសិក្សា ២០១៧/១៨។ អត្រានៃការទទួលបានការអប់រំ ជារួម មានលក្ខណៈមិនល្អសម្រាប់កុមារមកពីគ្រួសារក្រីក្រនៅជនបទ។ ការសិក្សាដែលត្រូវបានវាស់ដោយការធ្វើតេស្តជាស្តង់ដារ ក៏បង្ហាញផងដែរថានៅមានលទ្ធភាពកែលម្អ ជាពិសេសសម្រាប់គ្រួសារដែលជួបការលំបាក។

រាជរដ្ឋាភិបាលកម្ពុជា មានបំណងដោះស្រាយបញ្ហាប្រឈមនៃភាពក្រីក្រ និងសមធម៌ទាំងនេះ។ ផែនការយុទ្ធសាស្រ្តអប់រំឆ្នាំ ២០១៤-២០១៨ និង យុទ្ធសាស្រ្តជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដាក់ចេញនូវផែនការសម្រាប់គោលបំណងនេះ។ កម្មវិធីអាហារូបករណ៍ដែលគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា គឺជាកូនសោរនៃផែនការទាំងនេះ។ កម្មវិធីអាហារូបករណ៍ សំដៅជ្រើសរើសកុមារពីគ្រួសារក្រីក្រ ដែលកំពុងរៀននៅបឋមសិក្សាកម្រិតខ្ពស់ (ថ្នាក់ទី ៤ ដល់ ៦) ឬ មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧ ដល់ ៩) និង ផ្តល់ឲ្យកុមារទាំងនេះនូវប្រាក់ឧបត្ថម្ភបីដង ក្នុងមួយដងចំនួន ២០ ដុល្លារអាមេរិក រៀងរាល់ឆ្នាំ។ ដើម្បីបន្តទទួលបានអាហារូបករណ៍ សិស្សត្រូវទៅសាលាឲ្យបានទៀងទាត់ និង ទទួលបានលទ្ធផលសិក្សាល្អ។

គំនិតសំខាន់គឺថាប្រសិនបើគ្រួសារក្រីក្រទទួលបានអាហារូបករណ៍បន្ទាប់មក ពួកគេនឹងចាយកាន់តែច្រើន និងកាន់តែយកចិត្តទុកដាក់លើការអប់រំកូនរបស់ពួកគេ។ ជាលទ្ធផល កុមារនឹងទៅសាលាបានកាន់តែទៀងទាត់ និងត្រៀមលក្ខណៈបានកាន់តែប្រសើរឡើងដើម្បីរៀន។ ប្រសិនបើសាលាទាំងនេះ ដំណើរការល្អ នោះសិស្សទាំងនេះនឹងរៀនបានកាន់តែច្រើន។ ការរៀនបន្ថែមនេះគប្បីជួយពួកគេក្នុងការរកបានការងារល្អ ប្រសិនបើសេដ្ឋកិច្ចដំណើរការល្អ។ **'ទ្រឹស្តីនៃការផ្លាស់ប្តូរ'** នេះ បង្ហាញថាតើអាហារូបករណ៍ត្រូវបានរំពឹងថានឹងរួមចំណែកយ៉ាងដូចម្តេច ដល់ការអប់រំកាន់តែប្រសើរឡើង និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ក្នុងឆ្នាំសិក្សា ២០១៧/២០១៨ អាហារូបករណ៍ត្រូវបានផ្តល់ជូនសិស្សចំនួន ៨៦.១២៦ នាក់នៅសាលាបឋមសិក្សាចំនួន ៤.៦១១ ដែលនៅក្នុងនោះ ៥២% នៃសិស្សទាំងនេះ គឺជាកុមារី និងផ្តល់ជូនសិស្សចំនួន ៧១.៦៦៩ នាក់នៅអនុវិទ្យាល័យចំនួន ៨០៩ ដែលនៅក្នុងនោះ ៦០ ភាគរយនៃសិស្សទាំងនោះ គឺជាកុមារី។

*រូបទី ១: ចំនួនកុមារនៅក្រៅសាលា អាស៊ីអគ្នេយ៍*




មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)

## គោលបំណងនៃការវាយតម្លៃ

រាជរដ្ឋាភិបាលកម្ពុជានិងដៃគូ ចង់បានការវាយតម្លៃមួយដើម្បីពិនិត្យមើលថាតើកម្មវិធីអាហារូបករណ៍បានសម្រេចគោលដៅនៃអាហារូបករណ៍ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ ឬទេ និងដើម្បីពិនិត្យមើលថាតើមានការកែលម្អអ្វីឬទេដែលអាចធ្វើបានចំពោះការរៀបចំ ឬការផ្តល់អាហារូបករណ៍។ ជាពិសេស ការវាយតម្លៃត្រូវបាន រៀបចំដើម្បីរួមចំណែកដល់កិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍក្របខ័ណ្ឌអាហារូបករណ៍បឋមសិក្សាមួយដែលផ្តោតលើសមធម៌ ដែលត្រូវបញ្ចប់ក្នុងខែមីនា ឆ្នាំ ២០១៩។ ការវាយតម្លៃនេះ ក៏ឆ្លើយផងដែរនូវសំណួរជាក់លាក់មួយចំនួនពីក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថាតើ៖

- ប្រាក់ឧបត្ថម្ភគឺជាចំនួនត្រឹមត្រូវឬទេ និងត្រូវបានផ្តល់ទាន់ពេលឬទេ
- សិស្សដែលសមទទួលបានអាហារូបករណ៍ ត្រូវបានជ្រើសរើសឬទេ និង
- អាហារូបករណ៍បានជួយដល់ការឆ្លងភូមិសិក្សារបស់សិស្សពីបឋមសិក្សាកម្រិតខ្ពស់ទៅមធ្យមសិក្សាបឋមភូមិឬទេ។

## វិធីសាស្រ្តវាយតម្លៃ

ចាប់ផ្តើមក្នុងខែកញ្ញា ឆ្នាំ ២០១៨ ក្រុមវាយតម្លៃបានរៀបចំកម្រងសំណួរការវាយតម្លៃចុងក្រោយ ជាមួយក្រុមពិគ្រោះយោបល់ ដែលត្រូវបានដឹកនាំដោយអគ្គនាយកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា និង គ្រប់គ្រងដោយអង្គការយូនីសេហ្វ (UNICEF)។ សំណួរទាំងនេះ ត្រូវបានរៀបចំតាមលក្ខណៈវិនិច្ឆ័យរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍នៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (ហៅកាត់ថា OECD) សម្រាប់វាយតម្លៃជំនួយអភិវឌ្ឍន៍៖ ភាពសមស្រប ប្រសិទ្ធផល ប្រសិទ្ធភាព ផលប៉ះពាល់ និងនិរន្តរភាព។ ពីព្រោះគោលដៅជាក់លាក់នៃក្របខ័ណ្ឌផ្តោតលើសមធម៌ ការវាយតម្លៃនេះក៏ពិនិត្យមើលសមធម៌ផងដែរ។

បន្ទាប់មក ក្រុមវាយតម្លៃបានឯកភាពជាមួយក្រុមពិគ្រោះយោបល់លើវិធីសាស្រ្តមួយដើម្បីឆ្លើយសំណួរទាំងនេះ ដោយផ្អែកលើសំណើដំបូងរបស់ពួកគេ និងល័ក្ខខ័ណ្ឌយោងការងារ និង អនុលោមតាមនិយាមនិងស្តង់ដាររបស់ក្រុមវាយតម្លៃសហប្រជាជាតិ សម្រាប់ការវាយតម្លៃ (២០១៦)។

ដំបូង ក្រុមវាយតម្លៃរៀបចំឡើងវិញនូវទ្រឹស្តីនៃការផ្លាស់ប្តូរនៃកម្មវិធីអាហារូបករណ៍។ ក្រុមវាយតម្លៃបានប្រើទ្រឹស្តីនៃការផ្លាស់ប្តូរនេះ ដោយឡែកដើម្បីផ្តល់ព័ត៌មានដល់គោលវិធីចំពោះសំណួរអំពីប្រសិទ្ធភាព និងផលប៉ះពាល់ ដោយប្រមូលភស្តុតាងនៅគ្រប់កម្រិតនៃទ្រឹស្តីនេះចាប់ពីសកម្មភាពដល់ផលប៉ះពាល់។ ទ្រឹស្តីនៃការផ្លាស់ប្តូរ ក៏ជួយផងដែរដល់ការរៀបចំនិងដំណើរការសំណួរវាយតម្លៃដទៃទៀត។

ផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរនេះ ការវាយតម្លៃបានប្រើវិធីចម្រុះមួយដើម្បីឆ្លើយសំណួរវាយតម្លៃ។ ពីព្រោះការវាយតម្លៃពិនិត្យមើលត្រឡប់ក្រោយវិញពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ គេមិនអាចប្រើគោលវិធីសាកល្បងបានទេ។ ផ្ទុយទៅវិញ ការវាយតម្លៃបានផ្អែកលើ៖

- ❖ ឯកសារសិក្សាមានស្រាប់អំពីកម្មវិធីអាហារូបករណ៍ ដូចជាការវាយតម្លៃនិងការពិនិត្យមើលអាហារូបករណ៍ចាប់តាំងពីឆ្នាំ ២០០១ រួមទាំងការវាយតម្លៃសាកល្បងមួយដែលធ្វើដោយធនាគារពិភពលោក។
- ❖ ទិន្នន័យពាក់ព័ន្ធ ដូចជាប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអាហារូបករណ៍ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំរបស់ក្រសួង មូលដ្ឋានទិន្នន័យប័ណ្ណក្រីក្រនៃគ្រួសារក្រីក្រក្នុងប្រទេសកម្ពុជា និង អង្កេតតាមដានចំណាយសាធារណៈឆ្នាំ ២០១៦ និង
- ❖ ទិន្នន័យបឋមដែលប្រមូលដោយក្រុមវាយតម្លៃ ជាពិសេស អង្កេតមួយអំពីលំហូរនិងវិភាជន៍មូលនិធិដែលប្រមូលមកពីមន្ទីរអប់រំខេត្ត និងរតនាគារខេត្តនីមួយ ការសម្ភាសរៀបចំបើកទូលាយចំនួន ២៧ ឬការពិភាក្សាជាក្រុមជាមួយបុគ្គលិកអប់រំខេត្តនៅខេត្តចំនួនប្រាំ (សូមមើលរូបទី ១២) និងជាមួយបុគ្គលិកអប់រំស្រុកនៅស្រុកចំនួនដប់នៅក្នុងខេត្តទាំងប្រាំនោះ និង ការសម្ភាសរៀបចំបើកទូលាយ និងការពិភាក្សាជាក្រុមចំនួន ៣៦៣ ជាមួយមាតាបិតាសិស្ស កុមារ គ្រូបង្រៀន និងបុគ្គលិកអប់រំនៅសាលារៀនចំនួន ២៤ ក្នុងស្រុកចំនួនប្រាំបី។

*រូបទី 1: ទីកន្លែងនៃការវាយតម្លៃនៅមូលដ្ឋាន*



ការយកសំណាកសិក្សាត្រូវបានធ្វើដើម្បីកំណត់ខេត្តដែលតំណាងឲ្យតំបន់ទាំងបួន និងស្រុកផ្តល់នូវភាពឆ្ងាយដាច់ស្រយាលផ្សេងៗ និងអត្រាភាពក្រីក្រខ្ពស់។ ទិន្នន័យសម្ភាសន៍ ត្រូវបានវិភាគ និងផ្ទៀងផ្ទាត់ដោយក្រុមវាយតម្លៃ និងប្រៀបធៀបជាមួយព័ត៌មានមានស្រាប់ពីការវាយតម្លៃនានា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងទិន្នន័យដទៃទៀត ដើម្បីដកស្រង់ប្រធានបទនិងសេចក្តីសន្និដ្ឋានគន្លឹះនានា។

ដើម្បីផ្តល់ព័ត៌មានដល់ការសន្ទនាដែលកំពុងមាន ការវាយតម្លៃបានរៀបចំកំណត់ត្រារបកគំហើញដំបូង របាយការណ៍វាយតម្លៃបឋមមួយ និងរបាយការណ៍វាយតម្លៃចុងក្រោយមួយ ដែលត្រូវបានបញ្ជាក់សុពលភាពជាមួយភាគីពាក់ព័ន្ធសំខាន់ៗនៅរាជធានីភ្នំពេញ នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៩ និងត្រូវបានកែលម្អក្រោយពេលបានទទួលមតិយោបល់ពីក្រុមពិគ្រោះយោបល់។

## របកគំហើញសំខាន់ៗនៃការវាយតម្លៃ

ការវាយតម្លៃ សន្និដ្ឋានថាកម្មវិធីអាហារូបករណ៍មានលក្ខណៈសមស្របខ្ពស់ចំពោះតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា និងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូ។ កម្មវិធីអាហារូបករណ៍ទាំងនេះ មានសង្គតិភាពជាមួយឯកសារនិងអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៤-២០១៨ និងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥។ អាហារូបករណ៍មានលក្ខណៈបំពេញបន្ថែមលើកម្មវិធីដទៃទៀត ដោយហេតុថាវាមិនត្រួតស៊ីគ្នាជាមួយអាហារូបករណ៍ដទៃទៀតរបស់រាជរដ្ឋាភិបាលទេ និងជារួម ប្រើមូលដ្ឋានទិន្នន័យប័ណ្ណក្រីក្រដើម្បីជ្រើសរើសសិស្ស។ រូបទី បង្ហាញទំនាក់ទំនងសមហេតុផលមួយរវាងចំនួនគ្រួសារក្រីក្រនៅក្នុងខេត្ត និងចំនួនអាហារូបករណ៍។

*រូបទី ៣: អាហារូបករណ៍បឋមសិក្សា និងគ្រួសារក្រីក្រ*




ការវាយតម្លៃភាពសមស្របនៃទំហំអាហារូបករណ៍មួយ មិនមែនគឺជាវិទ្យាសាស្ត្រពិតទេ។ ការវាយតម្លៃប្រៀបធៀបទំហំនេះជាមួយនឹងទំហំអាហារូបករណ៍នៃកម្មវិធីដូចគ្នានៅប្រទេសដទៃ (សូមមើលរូបទី ៤) និង ជាមួយថ្លៃចំណាយនៃការអប់រំ (ឧទាហរណ៍ ឯកសណ្ឋានសិស្ស ឬ ការធ្វើដំណើរ) និងអ្វីដែលកុមារអាចរកបានប្រសិនបើមិនទៅសាលារៀន (សូមមើលរូបទី ៥)។ ក្រុមវាយតម្លៃក៏បានវិភាគផងដែរនូវទិន្នន័យសម្ភាសន៍នៅកម្រិតសាលារៀន និងការសិក្សាផ្សេងៗទៀត។ ផ្អែកលើការវិភាគនេះទំហំអាហារូបករណ៍បច្ចុប្បន្នហាក់បីដូចជាស្ថិតនៅក្នុងរង្វង់សមស្រប។

*រូបទី ៤: ប្រៀបធៀបអាហារូបករណ៍ជាមួយប្រទេសដទៃ*




*រូបទី ៥: ប្រៀបធៀបអាហារូបករណ៍ជាមួយថ្លៃចំណាយអប់រំ*




បច្ចុប្បន្ន អាហារូបករណ៍ត្រូវបានផ្តល់ជូនជាប្រាក់ជូនមាតាបិតាសិស្សនៅសាលារៀននៅក្នុងពិធីសាធារណៈមួយ។ ប្រការនេះ រួមចំណែកដល់ការលើកទឹកចិត្តសិស្សអាហារូបករណ៍ក្នុងលក្ខណៈវិជ្ជមាន។ ការឈានទៅប្រើប្រព័ន្ធបើកប្រាក់អេឡិចត្រូនិក នឹងកាត់បន្ថយឥទ្ធិពលវិជ្ជមាននេះ។

**ប្រសិទ្ធផល**នៃកម្មវិធីអាហារូបករណ៍អាចកែលម្អបាន។ មកដល់ពេលនេះ ការផ្ទេរប្រាក់អាហារូបករណ៍មិនត្រូវបានធ្វើនៅដើមឆ្នាំសិក្សាទេ។ ចំណុចនេះមានន័យថា សិស្សអាហារូបករណ៍មិនអាចទិញសម្ភារសិក្សានៅពេលដែលពួកគេត្រូវការសម្ភារទាំងនោះបំផុត

បានឡើយ និងមានន័យផងដែរថាសិស្សមិនបានទទួលការលើកទឹកចិត្តនៃការទទួលបានអាហារូបករណ៍ បានទាន់ពេលទេ។

ការផ្ទេរប្រាក់ មានការយឺតយ៉ាវដោយសារមូលហេតុសំខាន់ពីរ។ *បញ្ហាទីមួយ* គឺថាវិភាជន៍ថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺស្ថិតនៅក្នុងត្រីមាសទីមួយនៃឆ្នាំសារពើពន្ធដែលចាប់ផ្តើមក្នុងខែមករា ដែលមានន័យថាប្រាក់មិនបានទៅដល់រតនាគារខេត្តមុនខែកុម្ភៈ ទេសម្រាប់ឆ្នាំសិក្សាដែលចាប់ផ្តើមកាលពីខែ វិច្ឆិកា មុន។ នៅពេលនេះ បញ្ហានេះត្រូវបានដោះស្រាយដោយកិច្ចព្រមព្រៀងរវាងក្រសួងទាំងពីរ ដែលអាហារូបករណ៍នឹងទទួលបានវិភាជន៍ថវិកានៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំហិរញ្ញវត្ថុមុន។ *បញ្ហាទីពីរ* គឺពេលវេលាដែលត្រូវចំណាយសម្រាប់ឲ្យសាលាធ្វើអត្តសញ្ញាណកម្មសិស្សអាហារូបករណ៍ នៅដើមឆ្នាំសិក្សា ហើយបន្ទាប់មកបញ្ជូនឈ្មោះទៅថ្នាក់ស្រុកនិងខេត្ត។ បញ្ហានេះ នៅមិនទាន់បានដោះស្រាយនៅឡើយ និងទំនងជាមានន័យថា ការបើកប្រាក់អាហារូបករណ៍ដំបូងនឹងត្រូវបានធ្វើយ៉ាងឆាប់បំផុតនៅក្នុងខែមករា។

របកគំហើញចុងក្រោយអំពីប្រសិទ្ធផល គឺថាពុំមានវិភាជន៍ថវិកាសម្រាប់សោហ៊ុយធ្វើដំណើរសម្រាប់បុគ្គលិកសាលាដើម្បីការងារតាមដាន ឬ ការជ្រើសរើសសិស្សអាហារូបករណ៍នោះទេ។ ចំណុចនេះ កាត់បន្ថយផលប៉ះពាល់នៃអាហារូបករណ៍ តាមវិធីសំខាន់ៗបីយ៉ាង។ *ទីមួយ* បុគ្គលិកមិនអាចចុះសួរសិស្សដែលមិនមករៀនបានដោយងាយទេ ដូច្នេះ មិនដឹងថាតើត្រូវជួយពួកគេតាមរបៀបណា។ *ទីពីរ* ក្រសួងមានទិន្នន័យមានកម្រិតអំពីសិស្សអាហារូបករណ៍សម្រាប់រៀនសូត្រនិងកែលម្អ និងសម្រាប់ផ្សព្វផ្សាយជោគជ័យ។ *ទីបី* គ្រូបង្រៀនមិនអាចពិនិត្យមើលភាពសមស្របនៃការកំណត់គោលដៅ ដោយចុះដល់លំនៅឋានសិស្សឡើយ។ ចំណុចនេះ គឺជាបញ្ហាធំមួយ ជាពិសេស សម្រាប់សិស្សអនុវិទ្យាល័យដែលរស់នៅឆ្ងាយពីសាលា។

អាហារូបករណ៍ ត្រូវបានចាត់ទុកដោយសិស្សទទួលអាហារូបករណ៍ថាមានប្រសិទ្ធភាពណាស់។ សិស្សទទួលអាហារូបករណ៍ ជារួម មានសេចក្តីពេញចិត្តជាមួយអាហារូបករណ៍។ គេឃើញមានភស្តុតាងយ៉ាងច្បាស់ពីប្រភពផ្សេងៗដែលថា អាហារូបករណ៍បានរួមចំណែកដល់ប្រការដែលកុមារទៅរៀនបានយូរ និងមានកម្លាំងចិត្ត។ សិស្សប្រុសថ្នាក់ទី ៨ ម្នាក់មកពីខេត្តស្ទឹងត្រែង បាននិយាយថា *"ខ្ញុំមានកម្លាំងដើម្បីបន្តការសិក្សារបស់ខ្ញុំ។"*

ប៉ុន្តែ ការវាយតម្លៃមិនបានរកឃើញភស្តុតាងដែលថា អាហារូបករណ៍រួមចំណែកដល់ការកែលម្អលទ្ធផលសិក្សារបស់សិស្សអាហារូបករណ៍ទេ ពីព្រោះអាហារូបករណ៍តែមួយមុខ គឺមិនគ្រប់គ្រាន់ទេដើម្បីជំនះរាល់ឧបសគ្គទាំងអស់ចំពោះការសិក្សា។ម្យ៉ាងទៀត អាហារូបករណ៍ មិនអាចជំនះបានលើឧបសគ្គធំៗចំពោះការទៅរៀនទៀងទាត់ឡើយ ដូចជាវិបត្តិក្នុងគ្រួសារ ឬ សិស្សមិនចង់រៀន។

ការប្រាប់សិស្សអាហារូបករណ៍ថា ពួកគេត្រូវទៅរៀនឲ្យបានទៀងទាត់ដើម្បីទទួលបានអាហារូបករណ៍ បានជួយពង្រឹងប្រសិទ្ធភាពនៃអាហារូបករណ៍។ ល័ក្ខខ័ណ្ឌត្រូវទទួលបានលទ្ធផលល្អ កម្រត្រូវបានអនុវត្តណាស់ ហើយតាមទស្សនៈរបស់ក្រុមវាយតម្លៃ ការអនុវត្តល័ក្ខខ័ណ្ឌនេះនឹងមិនជួយដល់ការសម្រេចបាននូវគោលបំណងនៃអាហារូបករណ៍ទេ ពីព្រោះវានឹងដាក់ទណ្ឌកម្មដល់សិស្សដែលមិនពូកែ។

អាហារូបករណ៍ ត្រូវបានបែងចែកដល់ខេត្តនិងស្រុក ផ្អែកលើមូលដ្ឋាននៃភាពក្រីក្រ ដូចដែលមានបង្ហាញជូនក្នុងរូបទី ៣។ ប្រការនេះមិនរាប់បញ្ចូលគ្រួសារក្រីក្រដែលរស់នៅក្នុងស្រុក ដែលមានអត្រាភាពក្រីក្រទាប។ គេឃើញមានភាពខុសគ្នាច្រើននៅក្នុងរបៀបដែលសិស្សត្រូវបានជ្រើសរើស។ ថ្វីបើសិស្សអាហារូបករណ៍ទាំងអស់ត្រូវមានប័ណ្ណក្រីក្រក្តី ក៏នៅតាមសាលាភាគច្រើនបំផុតក្រុមវាយតម្លៃបានជួបសិស្សអាហារូបករណ៍ដែលមិនមានប័ណ្ណក្រីក្រ។ ជាធម្មតា នាយកសាលានិងគ្រូបង្រៀនប្រើការសម្រេចចិត្តរបស់ខ្លួនក្នុងការជ្រើសរើសសិស្សអាហារូបករណ៍ ដែលតំណាងឲ្យហានិភ័យមួយ ជាពិសេសស នៅអនុវិទ្យាល័យ ដែលគ្រូមិនសូវដឹងពីសាវតារសិស្សរបស់ខ្លួន។

ដោយពិនិត្យមើលផលប៉ះពាល់ គេឃើញមានភស្តុតាងច្បាស់ថាប្រាក់អាហារូបករណ៍ត្រូវបានចាយ ជាទូទៅដោយម្តាយឬជីដូនលើសម្ភារសិក្សា ឬ លើចំណាយផ្សេងៗ ឬ លើអាហារ។ ភស្តុតាងជារួម បង្ហាញថាអាហារូបករណ៍មានផលប៉ះពាល់វិជ្ជមានច្រើន។ ប៉ុន្តែ គេឃើញមានផលប៉ះពាល់អវិជ្ជមានខ្លះលើសិស្សមិនបានទទួលអាហារូបករណ៍ ដែលមានការច្រណែន ហើយក្នុងករណីខ្លះមានការបាក់ទឹកចិត្តដោយមិនត្រូវគេជ្រើសរើស។ ផលប៉ះពាល់អវិជ្ជមានទាំងនេះ បានកើនឡើងថែមទៀត នៅពេលដែលសាលាគូសបញ្ជាក់នូវភាពខុសគ្នារវាងសិស្សទទួលអាហារូបករណ៍ និងសិស្សមិនបានទទួលអាហារូបករណ៍។

អាហារូបករណ៍ មិនអាចគាំទ្រការឆ្លងភូមិសិក្សាពី បឋមសិក្សាកម្រិតខ្ពស់ទៅមធ្យមសិក្សាបឋមភូមិឡើយ ពីព្រោះកម្មវិធីអាហារូបករណ៍ទាំងនេះ មិនត្រូវបានសម្របសម្រួលបានល្អទេ។ ចំណុចនេះត្រូវបានបង្ហាញយ៉ាងសាមញ្ញដោយ រូបទី៦ ដែលបង្ហាញថាគ្មានទំនាក់ទំនងរវាងចំនួនអាហារូបករណ៍ថ្នាក់ទី៦ និងចំនួនអាហារូបករណ៍ថ្នាក់ទី៧ ដែលមានក្នុងខេត្តណាមួយឡើយ។ រូបទី៧ សង្ខេបរបកគំហើញអំពីប្រសិទ្ធភាព និង ផលប៉ះពាល់។

*រូបទី៦: សេចក្តីសង្ខេបអំពីលទ្ធផលប្រកបដោយប្រសិទ្ធភាព និងលទ្ធផលនៃផលប៉ះពាល់*




*រូបទី៧: អាហារូបករណ៍ថ្នាក់ទី៦ និងទី៧*




ជារួម និរន្តរភាពមានលក្ខណៈរឹងមាំ ជាមួយភាពជាម្ចាស់កម្រិតខ្ពស់របស់រាជរដ្ឋាភិបាល និងការប្រើធនធានហិរញ្ញវត្ថុនិងធនធានមនុស្សកម្ពុជា ដើម្បីដំណើរការកម្មវិធី។ ការពង្រីក នឹងទាមទារធនធាននិងសមត្ថភាពបន្ថែម និងការអភិវឌ្ឍនីតិវិធីថ្មីមួយចំនួនដើម្បីធានាឲ្យបាននូវការតភ្ជាប់គ្នារវាងបឋមសិក្សា និងមធ្យមសិក្សា។

ចំពោះសមធម៌ ក្រសួងមានទិន្នន័យតិចតួចតែប៉ុណ្ណោះអំពីអាហារូបករណ៍ដែលបែងចែកតាមភេទ។ ពុំមានកន្លែងប្រមូលផ្តុំទេសម្រាប់ទិន្នន័យស្តីពីអាហារូបករណ៍បឋមសិក្សានិងមធ្យមសិក្សា។

## សេចក្តីសន្និដ្ឋានសំខាន់ៗ

**ទស្សនៈរួម:** កម្មវិធីអាហារូបករណ៍កំពុងដំណើរការបានល្អដោយកែលម្អការទទួលបានការអប់រំ និង គឺជាប្រភពនៃមោទនភាពសម្រាប់មន្ត្រីក្រសួង បុគ្គលិកសាលា និង ប្រជាពលរដ្ឋជាអ្នកកាន់សិទ្ធិដែលទទួលអាហារូបករណ៍។ ប៉ុន្តែ គេឃើញមានវិស័យមួយចំនួន ដែលការរៀបចំនិងការអនុវត្តអាហារូបករណ៍អាចកែលម្អបាន រួមមានការបើកប្រាក់ឲ្យបានទាន់ពេល ការអនុវត្តប្រកបដោយប្រសិទ្ធភាព (ជាពិសេស ការកំណត់គោលដៅ) និង ការតាមដាន និងការផ្តល់មតិកែលម្អ។ អាហារូបករណ៍យកចិត្តទុកដាក់លើសមធម៌ក្នុងការជ្រើសរើស និងការចាត់ចែង ប៉ុន្តែ មានការតាមដានសមធម៌ (ឬ ការតាមដានជាទូទៅ) តិចតួច។

**គោលបំណង:** កុមារត្រូវបានរក្សានៅក្នុងសាលា ដែលជាលទ្ធផលនៃការអនុវត្តប្រកបដោយប្រសិទ្ធភាពជារួម និងដោយសារវប្បធម៌ដែលគាំទ្រខ្លាំងដល់ការអប់រំ។ ប៉ុន្តែ អាហារូបករណ៍មានដោយប្រសិទ្ធភាពតិច ក្នុងការគាំទ្រការឆ្លងភូមិសិក្សាពីបឋមសិក្សាទៅអនុវិទ្យាល័យ ហើយសិស្សខ្លះនៅតែមិនទៅរៀនឲ្យបានទៀងទាត់ បើទោះបីជាបានទទួលអាហារូបករណ៍ក្តី។

**ឧបសគ្គចំពោះប្រសិទ្ធភាព:** ការសម្របសម្រួលមានលក្ខណៈមានកម្រិតរវាងអាហារូបករណ៍បឋមសិក្សា និងអាហារូបករណ៍មធ្យមសិក្សា ការបើកប្រាក់យឺត ថ្លៃចំណាយឱកាសខ្ពស់នៃការអប់រំ ជាពិសេសនៅមធ្យមសិក្សា និង ការលំបាកនៃការដាក់បន្ថែមសិស្សដែលបោះបង់ការសិក្សា ក្រោយពេលមានវិបត្តិប្រាក់ចំណូលចំពោះគ្រួសារពួកគេ។

**ការលំបាក:** កិច្ចដំណើរការជ្រើសរើស និងបើកប្រាក់ដ៏វែងអន្លាយ និង ការប្រមូលនិងគ្រប់គ្រងព័ត៌មានស្តីពីអាហារូបករណ៍ ជាពិសេស ព័ត៌មានជាក់លាក់អំពីសិស្ស។

**ចំណុចខ្លាំង:** ការគាំទ្រទូលាយដែលពួកគេបានទទួលក្នុងទូទាំងប្រទេសកម្ពុជា។ ក្រៅពីនាយកសាលាតូចៗមួយចំនួនដែលយល់ថាការអនុវត្តអាហារូបករណ៍គឺជាបន្ទុកមួយ អ្នកឆ្លើយតបមានសេចក្តីពេញចិត្ត និងមានភាពជាម្ចាស់ខ្ពស់លើអាហារូបករណ៍។ កិច្ចដំណើរការស្នូល មានប្រសិទ្ធភាព: សិស្ស

មកពីគ្រួសារក្រីក្រត្រូវបានកំណត់អត្តសញ្ញាណ និង បើកប្រាក់ជូន ៦០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ហើយប្រាក់នេះជួយពួកគេឲ្យស្ថិតនៅសាលារៀន និងជំរុញឲ្យពួកគេខំរៀន។

**ចំណុចខ្សោយៈ** ការបើកប្រាក់យឺត ការសម្របសម្រួលមិនបានល្អរវាងអាហារូបករណ៍បឋមសិក្សានិងអាហារូបករណ៍មធ្យមសិក្សា ភាពមិនសុក្រឹតនៅក្នុងការកំណត់គោលដៅ និង ការតាមដាន ការផ្តល់មតិកែលម្អ និង ទំនាក់ទំនងទន់ខ្សោយ។

**ភាពមិនច្បាស់លាស់ៈ** ភាពទន់ភ្លន់ដែលផ្តល់ឲ្យអ្នកកាន់ភារកិច្ចនៅថ្នាក់សាលារៀន ជាពិសេស នាយកសាលា។ នៅទីណាដែលអ្នកកាន់ភារកិច្ចទាំងនេះមានការតាំងចិត្តខ្ពស់ មិនគិតប្រយោជន៍ផ្ទាល់ខ្លួន និងបានទទួលព័ត៌មានគ្រប់គ្រាន់ ភាពទន់ភ្លន់នេះគឺជាចំណុចខ្លាំងមួយ។ នៅទីណាដែលពួកគេមិនមានចរិតលក្ខណៈបែបនេះ នោះវាគឺជាចំណុចខ្សោយមួយ។ ការអនុវត្តល្អនិងនវានុវត្តន៍ដែលអាចពង្រីកក្នុងកម្មវិធីទាំងមូល ទោះបីជាចំណុចនេះមិនមានលក្ខខណៈងាយយល់ក៏ដោយ។

## មេរៀនដែលបានទទួល

មានមេរៀនគួរឲ្យចាប់អារម្មណ៍មួយចំនួនពីការវាយតម្លៃដែលមានលក្ខណៈសមស្របនៅកន្លែងផ្សេងៈ

**ភាពសមស្របៈ** មាតាបិតានិងសិស្សកម្ពុជា មានក្តីប្រាថ្នានិងក្តីរំពឹងខ្ពស់ចំពោះតួនាទីនៃការអប់រំក្នុងការជួយរកបានការងារល្អ។ ក្តីរំពឹងទាំងនេះ នឹងមានលក្ខណៈលំបាកក្នុងការសម្រេចបាន បើគ្មានសាលាមានគុណភាពល្អ និងបើគ្មានការងារ។ ប៉ុន្តែ វាផ្តល់នូវមូលដ្ឋានដ៏ល្អមួយសម្រាប់រៀបចំនិងអនុវត្តកម្មវិធីអប់រំពាក់ព័ន្ធ។

**ប្រសិទ្ធភាពៈ** អាហារូបករណ៍មានប្រសិទ្ធភាពក្នុងការពង្រឹងទស្សនៈវិជ្ជមានទាំងនេះអំពីការអប់រំ។ ប៉ុន្តែ អាហារូបករណ៍មិនទំនងជាអាចដោះស្រាយបញ្ហាបោះបង់ការសិក្សាបានទាំងស្រុងទេ សូម្បីតែវាផ្តល់ប្រាក់អាហារូបករណ៍ច្រើនក្តី។ សិស្សនឹងបន្តបោះបង់ការសិក្សា ពីព្រោះគ្រួសារធ្វើចំណាកស្រុក ឬមានបញ្ហាសុខភាព ឬបញ្ហាប្រឈមផ្សេងៗទៀត។ មានព្រំដែនចំពោះប្រសិទ្ធភាពនៃកម្មវិធីអាហារូបករណ៍នៅក្នុងបរិបទនៃភាពក្រីក្រ ការធ្វើចំណាកស្រុក និងបញ្ហាជាមួយគុណភាពសាលារៀន។ ប្រការនេះ មានលក្ខណៈស្របគ្នាជាមួយនឹងការសិក្សាអំពីកុមារនៅក្រៅសាលានៅកម្ពុជា និងនៅប្រទេសដទៃទៀត។

**ប្រសិទ្ធផលៈ** កម្មវិធីអាហារូបករណ៍មាន មានទម្រង់ច្រើននៅសាលាផ្សេងៗគ្នា ដែលគឺជាប្រភពនៃចំណុចខ្លាំងផង និងចំណុចខ្សោយផងសម្រាប់កម្មវិធីនេះ។ ជាស្តែង ចំណុចនេះមានន័យថា ប្រសិទ្ធផលនៃការអនុវត្ត – និង ប្រសិទ្ធភាព ផលប៉ះពាល់ និងសមធម៌នៅពេលបន្ទាប់ – ត្រូវបានសម្រេចយ៉ាងច្រើនដោយអ្នកកាន់ភារកិច្ចកម្រិតមូលដ្ឋាន។ ចំណុចនេះមានលក្ខណៈធម្មតានៅក្នុងកម្មវិធីជាច្រើន និង ចំពោះការផ្តល់សេវា ជាពិសេស នៅក្នុងវិស័យអប់រំ ដែលនៅក្នុងនោះ 'ការសម្រេចចិត្តរបស់បុគ្គលិកជួរមុខ' គឺសំខាន់ (ឧទាហរណ៍ ចំពោះការបង្រៀនល្អ)។ ចំណុចនេះដំណើរការបានល្អ នៅទីណាដែលគ្រូបង្រៀននិងនាយកសាលា មានទាំងចំណេះដឹងផង ទាំងការយកចិត្តទុកដាក់ផង និងដំណើរការមិនបានល្អ នៅទីណាដែលពួកគេមិនមានចរិតលក្ខណៈដូចនេះ។ អាស្រ័យហេតុនេះ វាតម្រូវឲ្យមានការតាមដាន ការបណ្តុះបណ្តាល និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ កម្មវិធីអាហារូបករណ៍មិនបានវិនិយោគគ្រប់គ្រាន់លើ ចំណុចទាំងនេះ ហើយប្រការនេះមិនមានប្រសិទ្ធផលឡើយ។

**និរន្តរភាពៈ** អ្នកកាន់សិទ្ធិនិងអ្នកកាន់ភារកិច្ច បានផ្តោតលើសារៈសំខាន់នៃសមធម៌ និងសមភាព។ ចំណុចនេះ គឺមានលក្ខណៈធម្មតានៅក្នុងប្រទេសជាច្រើន ជាពិសេសនៅតំបន់ជនបទ។ ចំណុចនេះមានផលប៉ះពាល់លើការពង្រីក ការកំណត់គោលដៅ និង ការកំណត់ទំហំនៃការផ្ទេរប្រាក់អាហារូបករណ៍ – ជាទូទៅ អ្នកកាន់សិទ្ធិ និងអ្នកកាន់ភារកិច្ចកម្រិតមូលដ្ឋានចង់ឲ្យមានប្រជាពលរដ្ឋចំនួនច្រើនទទួលបានប្រាក់ផ្ទេរតិច ជាងប្រជាពលរដ្ឋចំនួនតិចទទួលបានប្រាក់ផ្ទេរច្រើន។

**សមធម៌ៈ** អវត្តមាននៃព័ត៌មានកុមារជាក់លាក់នៅកម្ពុជា (ឧទាហរណ៍ ការមិនមានព័ត៌មានកុមារជាក់លាក់នៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) រារាំងប្រសិទ្ធភាពអាហារូបករណ៍ ក៏ដូចជាទិដ្ឋភាពផ្សេងៗទៀតនៃការផ្តល់សេវាអប់រំ។

## អនុសាសន៍

អនុសាសន៍សំខាន់បំផុត គឺថាកម្មវិធីអាហារូបករណ៍ គប្បីត្រូវបន្តនិងកែលម្អ។ លើសពីនេះៈ



១. **ការបើកប្រាក់ឲ្យបានទាន់ពេលៈ** វិធានការសំខាន់ៗមួយចំនួន ត្រូវបានអនុវត្តរួចហើយដើម្បីកែលម្អភាពទាន់ពេល។ ប៉ុន្តែ ក្រសួងអប់រំ យុវជន និងកីឡា គប្បីយកចិត្តទុកដាក់បន្ថែមទៀតលើបញ្ហានេះ។ ជាពិសេស ក្រសួងគប្បីបង្រួញនីតិវិធី ដែលនៅក្នុងនោះ ១) សាលាជ្រើសរើសសិស្សផ្ញើបញ្ជីនេះទៅថ្នាក់ស្រុកនិងខេត្ត និង ២) មន្ទីរអប់រំខេត្តដកប្រាក់ផ្ទេរពីរតនាគារខេត្ត។ តាមវិធីនេះ ការបើកប្រាក់អាហារូបករណ៍លើកទីមួយ គប្បីត្រូវធ្វើឲ្យបានមុនពាក់កណ្តាលខែមករា រាល់ឆ្នាំ ដោយចាប់ផ្តើមក្នុងឆ្នាំ ២០២០។

២. **សង្គតិភាពៈ** ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នូវសៀវភៅណែនាំលម្អិត

មួយសម្រាប់អ្នកកាន់ភារកិច្ចនៅកម្រិតសាលា ដែលដាក់បញ្ចូលរាល់សកម្មភាពទាំងអស់ និងរៀបចំផែនការដើម្បីផ្តល់ការបណ្តុះបណ្តាលជូនអ្នកកាន់ភារកិច្ចសំខាន់ៗ ឲ្យបានមុនខែ វិច្ឆិកា ឆ្នាំ ២០១៩។ លើសពីនេះ ក្រសួងគប្បីផ្សព្វផ្សាយតាមរយៈមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក ថាសាលាមិនគប្បីដាក់ស្លាកសិស្សអាហារូបករណ៍នៅក្នុងថ្នាក់ទេ និង គប្បីកុំសូវបង្ហាញក្នុងថ្នាក់រៀនថាមានសិស្សខ្លះបានទទួលអាហារូបករណ៍។

**៣. ការកំណត់គោលដៅ៖** ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំនិងអនុវត្ត ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នូវមូលដ្ឋានប្រកបដោយសង្គតិភាពមួយសម្រាប់ការបែងចែកអាហារូបករណ៍ទៅឲ្យខេត្ត ស្រុក និង សាលានៅក្នុងកម្មវិធីអាហារូបករណ៍បឋមសិក្សា និងអាហារូបករណ៍មធ្យមសិក្សា។ ចំណុចនេះគប្បីរាប់បញ្ចូលការបែងចែកអាហារូបករណ៍បឋមសិក្សា និងអាហារូបករណ៍មធ្យមសិក្សាទៅឲ្យស្រុក ដោយផ្អែកលើមូលដ្ឋាន (ដូចគ្នា) នៃភាពក្រីក្រ ឬ សូចនាករអប់រំ។ បន្ទាប់មក ស្រុកគប្បីបែងចែកអាហារូបករណ៍ទៅឲ្យសាលា ដោយផ្អែកលើមូលដ្ឋាននៃភាពក្រីក្រ សូចនាករអប់រំ (ដូចជាអត្រាបោះបង់ការសិក្សា ជាដើម) និង ទំនាក់ទំនងរវាងសាលាបឋមសិក្សា និងអនុវិទ្យាល័យ ដើម្បីធានាឲ្យបាននូវការឆ្លងភូមិសិក្សា (សូមមើលអនុសាសន៍ ៥)។ ក្រសួងអប់រំ យុវជន និងកីឡា គប្បីផ្តល់គោលការណ៍ណែនាំច្បាស់លាស់សម្រាប់ឲ្យសាលាជ្រើសរើស សិស្ស ដោយផ្អែកលើមូលដ្ឋាននៃភាពក្រីក្រ (រួមទាំងប័ណ្ណក្រីក្រ) និង ការទៅរៀន និងផ្តល់ថវិកាសម្រាប់ឲ្យបុគ្គលិកសាលាចុះតាមផ្ទះដើម្បីផ្ទៀតផ្ទាត់ស្ថានភាពភាពក្រីក្ររបស់គ្រួសារ។ កូតាផ្អែកលើយេនឌ័រ គប្បីត្រូវលុបចោល។

**៤. ការតាមដាន និងការរៀនសូត្រកែលម្អ៖** ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំយុទ្ធសាស្ត្រតាមដាននិងសិក្សាមួយដែលមានកំណត់ថ្លៃចំណាយសម្រាប់កម្មវិធីអាហារូបករណ៍ សម្រាប់ការផ្តល់ហិរញ្ញប្បទានដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០២០/២០២១។ ចាប់ពីឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡា គប្បីវិនិយោគលើការផ្សព្វផ្សាយអំពីសិទ្ធិ និងសិទ្ធិទទួលបាន ប្រព័ន្ធផ្តល់មតិកែលម្អ និងការប្រើទិន្នន័យទាំងនេះ ដើម្បីជួយឲ្យអ្នកកាន់សិទ្ធិដឹងអំពីសិទ្ធិរបស់ពួកគេ និងអាចដាក់បណ្តឹង ប្រសិនបើសិទ្ធិទាំងនេះមិនត្រូវបានបំពេញ ហើយអ្នកកាន់ភារកិច្ចឆ្លើយតបទៅនឹងបណ្តឹងទាំងនេះ។ ក្រសួងទាំងពីរគប្បីឯកភាពគ្នាក្នុងការបង្កើនថវិកាសម្រាប់ការតាមដានសិស្ស។

**៥. ការសម្របសម្រួល៖** ក្រសួងអប់រំ យុវជន និងកីឡា គប្បីដាក់បញ្ចូលនៅក្នុងក្របខ័ណ្ឌអាហារូបករណ៍កែសម្រួលឡើងវិញ ក្នុងឆ្នាំ ២០១៩ នូវការតាំងចិត្តមួយក្នុងការរៀបចំយុទ្ធសាស្ត្រមួយ សម្រាប់ឲ្យកម្មវិធីអាហារូបករណ៍អាចគាំទ្រសិស្សក្នុងការឆ្លងភូមិសិក្សាពីថ្នាក់ទី៦ ទៅថ្នាក់ទី៧ ឲ្យបានកាន់តែប្រសើរឡើង។ យុទ្ធសាស្ត្រឆ្លងភូមិសិក្សារយៈពេលវែងមួយ តម្រូវឲ្យមានអត្តសញ្ញាណកម្មមានតែមួយសម្រាប់សិស្ស ដែល ក្រសួងអប់រំ យុវជន និងកីឡា គប្បីធ្វើការវិនិយោគ។ សម្រាប់រយៈពេលខ្លី ក្រសួងអប់រំ យុវជន និងកីឡា គប្បីធ្វើការសាកល្បង និងវាយតម្លៃគោលវិធីមួយនៃការកែលម្អការឆ្លងភូមិសិក្សាក្នុងស្រុកតែមួយ។

**៦. ល័ក្ខខ័ណ្ឌ៖** ក្នុងឆ្នាំ ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា គប្បីលុបចោលល័ក្ខខ័ណ្ឌដែលកំណត់ឲ្យសិស្សទទួលអាហារូបករណ៍សម្រេចបានលទ្ធផលសិក្សាល្អ។ ល័ក្ខខ័ណ្ឌតម្រូវឲ្យទៅរៀនទៀតទាត់ គប្បីត្រូវរក្សាទុក ប៉ុន្តែ គ្រូបង្រៀនគប្បីបន្តអនុវត្តល័ក្ខខ័ណ្ឌនេះដោយប្រយ័ត្នប្រយែង និងជួយគាំទ្រសិស្សដែលជួបការលំបាកក្នុងការមករៀនដោយសារមូលហេតុសមស្រប។

Ian MacAuslan, ប្រធានក្រុមផ្នែកអប់រំ Oxford Policy Management

ដោយមានជំនួយពីសមាជិកក្រុមផ្សេងទៀតមកពី Oxford Policy Management (Russell Craig, Maham Farhat និង សារឿន ហ៊ុយ) និង ក្រុមហ៊ុន BN Consult (បណ្ឌិត សេង ប៊ុនលី)

សម្រាប់ទទួលបានរបាយការណ៍ទាំងស្រុង សូមចូលមើល https://www.unicef.org/cambodia